**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

លេខ 17-02-2025 អ.ប.ម.អ.ក

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល លេខ 343
ថ្ងៃ 20-02-25 9h:00
ម៉ោង

**សូមគោរពជូន**

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** : របាយការណ៍ស្តីពីសកម្មភាពការងារ និងហិរញ្ញវត្ថុរបស់អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា ប្រចាំឆ្នាំ២០២៤។

**យោង** : លិខិតលេខ .២៥១២ សជណ ចុះថ្ងៃទី១២ ខែ.ធ្នូ ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថាអង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា បានចុះបញ្ជីរួចហើយនៅក្រសួងមហាផ្ទៃ។ ក្នុងឆ្នាំ២០២៤កន្លងមកនេះ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា បានធ្វើសកម្មភាពស្របតាមលក្ខន្តិកៈ និងបានអនុវត្តថវិកាលើសកម្មភាពដូចក្នុងរបាយការណ៍គោរពជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអភិសន្តិបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃ ចន្ទ ៥រោច ខែមាឃ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨
សៀមរាប, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៥
**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

**ប្រធានអង្គការ**

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា
Pagna Cambodian Education Fund
P.C.E.F

**ស្រី សំបូរ**

***សូមជូនភ្ជាប់មកជាមួយនូវ ៖***

- លិខិតចុះបញ្ជីអង្គការ ០១ច្បាប់
- របាយការណ៍ឆ្នាំ២០២៤ ០១ច្បាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤


<u>អាសយដ្ឋាន</u> ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A ឃុំ ត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្ត សៀមរាប ។
<u>ទូរស័ព្ទទំនាក់ទំនង</u> ៖០១១ ២១ ៨០០៨ /០១៥ ២១ ៨០០៨ Email: pagna.pcef.cambodia@gmail.com

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

លេខ 17-02-2025 **អ.ប.ម.អ.ក**

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** : របាយការណ៍ស្តីពីសកម្មភាពការងារ និងហិរញ្ញវត្ថុរបស់អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា ប្រចាំឆ្នាំ២០២៤។

**យោង** : លិខិតលេខ ២៥១២ សជណ ចុះថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថាអង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា បានចុះបញ្ជីរួចហើយនៅក្រសួងមហាផ្ទៃ។

ក្នុងឆ្នាំ២០២៤កន្លងមកនេះ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជាបានធ្វើសកម្មភាពស្របតាមលក្ខន្តិកៈនិងបានអនុវត្តថវិកាលើសកម្មភាពដូចក្នុងរបាយការណ៍គោរពជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃ ចន្ទ ៥រោច ខែមាឃ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

សៀមរាប, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៥

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

**ប្រធានអង្គការ**

ស្រី សំបូរ

***សូមជូនភ្ជាប់មកជាមួយនូវ ៖***

- លិខិតចុះបញ្ជីអង្គការ ០១ច្បាប់
- របាយការណ៍សកម្មភាឆ្នាំ២០២៤ ០១ច្បាប់
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A ឃុំ ត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្ត សៀមរាប ។

ទូរស័ព្ទទំនាក់ទំនង ៖០១១ ២១ ៨០០៨ /០១៥ ២១ ៨០០៨ Email: pagna.pcef.cambodia@gmail.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

លេខ 17-02-2025 **អ.ប.ម.អ.ក**

## របាយការណ៍ប្រចាំ ឆ្នាំ២០២៤
## គម្រោងដែលអនុវត្តដោយផ្ទាល់
## របស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

### សេចក្តីផ្តើម

នៅដើមឆ្នាំ២០២៤ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចាប់ផ្តើមបន្តគម្រោងរបស់ខ្លួននៅក្នុងឆ្នាំសិក្សាថ្មី ដោយបន្តគម្រោងបង្រៀនភាសារអង់គ្លេសក្នុងឆ្នាំ២០២៤ នេះព្រោះយើងនៅតែមានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និង សំភារៈ ពីម្ចាស់ជំនួយនានាទាំងក្នុង និង ក្រៅប្រទេស **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានខិតខំបំពេញការងារលើគម្រោងអប់រំសំរាប់កុមារនៅក្នុងតំបន់គោលដៅរបស់ខ្លួនរហូតទទួលបានលទ្ធផលដ៏ល្អ ដែលអង្គការសូមរាយការណ៍ជូនខាងក្រោម៖

## ក. កម្មវិធីអប់រំភាសាអង់គ្លេស ដោយឥតគិតថ្លៃ

### ក.១ សេចក្តីផ្តើម

នៅពេលសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ យុវជន និង កីឡា បានចាប់ផ្តើមបើកបវេសនកាល សម្រាប់ឆ្នាំថ្មី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏បានចាប់ផ្តើមសកម្មភាពជាថ្មីសម្រាប់ឆ្នាំថ្មីផងដែរ ដើម្បីបន្តជួយបណ្តុះបណ្តាល ភាសា អង់គ្លេស ដល់កុមារាកុមារី សិស្សានុសិស្ស នៅក្នុងសហគមន៍ជារៀងរាល់ថ្ងៃដោយឥតគិតថ្លៃ ដោយមានការជួយឧបត្ថម្ភពីមូលនិធិសប្បុរសធម៌អាយហ៊ើប (IHERB) តាមរយៈអង្គការ CCAFO និងសប្បុរសជននានា នោះ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានបន្តគម្រោងអប់រំផ្នែកភាសាអង់គ្លេសដោយមិនយកកម្រៃ សម្រាប់សិស្សសាលាមកពី សាលាបឋមសិក្សា និងអនុវិទ្យាល័យ ស្ថិតក្នុងឃុំចំនួនបីគឺ ត្រពាំងធំ និង ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ហើយនិង ឃុំមួយផ្សេងទៀត គឺឃុំខ្វាស់ ស្រុកសូទ្រនិគមន៍ខេត្តសៀមរាប។

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

## ក.២ ស្ថិតិគ្រូ និង សិស្ស

នៅដើមខែមករាឆ្នាំ ២០២៤ កម្មវិធីសិក្សាសម្រាប់ឆ្នាំថ្មីបានចាប់ផ្តើម ដោយមានគ្រូសរុបចំនួន៨នាក់ (ស្រី៥នាក់) ដែលកំពុងតែបន្តធ្វើការជាមួយគ្នា ហើយក៏មានគ្រូបីនាក់ដែលធ្លាប់ជាសិស្សដែលបានរៀនចប់ពី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** របស់យើងផងដែរ ។

ក្នុងឆ្នាំ២០២៤នេះយើងមានសិស្សសរុបទាំងពីរសាខាចំនួន៨០៤នាក់ (សិស្សស្រីចំនួន ៤៧៧នាក់) ដែលបានចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង។

សម្រាប់កម្មវិធីឆ្នាំ២០២៤ កម្មវិធីបង្រៀនទាំងអស់ត្រូវបានបន្តទៅលើស្ថានភាពជាក់ស្តែងជាមួយសិស្សជាច្រើនដែលបានចូលរួម។

## ក.៣ ទីតាំងទី១ នៅ ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សទៅជា ១៤ ថ្នាក់ ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៤ថ្នាក់ ជាមួយការបង្រៀនចាប់ផ្តើមពីម៉ោង 7.30ព្រឹក ដល់ម៉ោង១០.៣០ព្រឹក (មួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះ)។ សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៤ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះដូចគ្នា ដោយចាប់ពីម៉ោង ១រសៀល ដល់ម៉ោង៤ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៦ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោង ដោយចាប់ពីម៉ោង ៦យប់ ដល់ម៉ោង៨យប់។

នៅតាំងទី១ ក្នុង ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២៤យើងមានសិស្សចំនួន ៤៧៧នាក់ (សិស្សស្រីចំនួន ២៨២ នាក់) ចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើងប៉ុន្តែមកដល់ចុងឆ្នាំ២០២៤ គម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ៣៦៤ នាក់ ស្រីចំនួន ២១៤នាក់។

ចំនួនសិស្សដែលបានបញ្ចប់ថ្នាក់មានចំនួន ៤១នាក់ សិស្សស្រីចំនួន ២៦នាក់

សិស្សដែលបោះបង់សាលាមានចំនួន ៧៩នាក់ ស្រី ៣៨នាក់។

ទ្រឹម តំបន្ទូន

អាសយដ្ឋាន ៖ ផ្ទះលេខ............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

| ទីតាំងទី១ នៅភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះគ្រូ | កាលវិភាគបង្រៀន | ម៉ោង | ឈ្មោះសៀវភៅ | កំរិតសៀវភៅដែលត្រូវរៀន | ចំនួនសរុប | ស្រី | អាយុ |
| ឡេង សែរង្ស | ព្រឹក | 7.30-9.00 | សៀវភៅ | ABC | 28 | 18 | 7 ទៅ 9 ឆ្នាំ |
| | | 9.00-10.30 | សៀវភៅ | ABC | 20 | 7 | 8 ទៅ 10 ឆ្នាំ |
| ជិម ចំរុង | | 7.30-9.00 | Family&Friends | Starter | 20 | 12 | 9 ទៅ 11 ឆ្នាំ |
| | | 9.00.10.30 | Family&Friends | Starter | 21 | 11 | 10 ទៅ 12 ឆ្នាំ |
| លយ គីមឡាង | ល្ងាច | 1.00-2.30 | សៀវភៅ | ABC | 49 | 32 | 7 ទៅ 9 ឆ្នាំ |
| | | 2.30-4.00 | សៀវភៅ | ABC | 51 | 22 | 8 ទៅ 10 ឆ្នាំ |
| ឡេង សែរង្ស | ល្ងាច | 1.00-2.00 | Family&Friends | Starter | 33 | 16 | 9 ទៅ 11 ឆ្នាំ |
| | | 2.00-3.00 | Family&Friends | Starter | 33 | 17 | 10 ទៅ 12 ឆ្នាំ |
| ស៊ិន សុភ័ក្តិ | យប់ | 6.00-7.00 | Family&Friends | Level 1 | 39 | 23 | 12 ទៅ 14 ឆ្នាំ |
| | យប់ | 7.00-8.00 | Family&Friends | Level 2 | 68 | 46 | 13 ទៅ 15 ឆ្នាំ |
| ជិម ចំរុង | យប់ | 6.00-7.00 | Family&Friends | Level 3 | 25 | 20 | 13 ទៅ 16 ឆ្នាំ |
| | | 7.00-8.00 | Family&Friends | Level 4 | 50 | 34 | 14 ទៅ 17 ឆ្នាំ |
| ឡេង សែរង្ស | យប់ | 6.00-7.00 | Family&Friends | Level 5 | 22 | 12 | 15 ទៅ 18 ឆ្នាំ |
| | | 7.00 -8.00 | Family&Friends | Level 6 | 18 | 12 | 15 ទៅ 19 ឆ្នាំ |
| | | | | សរុបនៅភូមិល្វា | 477 | 282 | |
| | | | | សិស្សបោះបង់សាលា | 79 | 38 | |

## ក.៤ ទីតាំងទី២ នៅភូមិគោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សជា១០ក្រុម ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៣ថ្នាក់ ជាមួយការបង្រៀន ចាប់ផ្ដើមពីម៉ោង ៨.០០ព្រឹក ដល់ម៉ោង១១.០០ព្រឹក (មួយថ្នាក់ត្រូវបង្រៀន ១ម៉ោង)។
សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៣ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោង ដោយចាប់ពីម៉ោង ១រសៀល ដល់ម៉ោង៤ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៤ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោងផងដែរ ដោយចាប់ពីម៉ោង ៤រសៀល ដល់ម៉ោង៨យប់។

នៅតាំងទី២ ក្នុង ភូមិគោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២៤ យើងមានសិស្សចំនួន ៣២៧ នាក់ (ស្រីចំនួន ១៩៥នាក់) បានចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង ប៉ុន្តែមកដល់ចុងឆ្នាំ២០២៤៣ កម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ២៧១នាក់ ស្រីចំនួន ១៥៥នាក់។

ចំនួនសិស្សដែរបោះបង់សាលាចំនួន ៥៥នាក់ ស្រី ៣៨នាក់។

| ទីតាំងទី២ នៅភូមិ គោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះគ្រូ | កាលវិភាគបង្រៀន | ម៉ោង | ឈ្មោះសៀវភៅ | កំរិតសៀវភៅដែលត្រូវរៀន | ចំនួនសរុប | ស្រី | អាយុ |
| ណូត ស្រីល័ក្ខ | ព្រឹក | 8.00-9.00 | សៀវភៅ | ABC | 52 | 21 | 6 ទៅ 8 ឆ្នាំ |
| ណូត ស្រីល័ក្ខ | | 9.00-10.00 | Family&Friends | Starter | 35 | 22 | 8 ទៅ 10 ឆ្នាំ |
| ឡេង សុវិន | | 10.00-11.30 | Family&Friends | Level 1 | 21 | 15 | 10 ទៅ 13 ឆ្នាំ |
| លាង សុនាត | រសៀល | 1.00-2.00 | សៀវភៅ | ABC | 53 | 30 | 6 ទៅ 8 ឆ្នាំ |
| លាង សុនាត | | 2.00-3.00 | Family&Friends | Starter | 19 | 11 | 8 ទៅ 10 ឆ្នាំ |
| | | | Family&Friends | Level 1 | 32 | 13 | |
| ឡេង សុវិន | | 3.00-4.00 | Family&Friends | Level 2 | 32 | 23 | 10 ទៅ 13 ឆ្នាំ |
| លាង សុនាត | | 5.00-6.00 | Family&Friends | Level 3 | 37 | 22 | 13 ទៅ 15 ឆ្នាំ |
| ឡេង សុវិន | យប់ | 6.00-7.00 | Family&Friends | Level 4 | 19 | 14 | 13 ទៅ 15 ឆ្នាំ |
| ឡេង សុវិន | | 7.00-8.00 | Family&Friends | Level 5 | 27 | 24 | 15 ទៅ 17 ឆ្នាំ |
| | | | | សិស្សសុប | 327 | 195 | |
| | | | | សិស្សបោះបង | 55 | 38 | |

## ក.៥ សកម្មភាពទូទៅរបស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

សកម្មភាពបង្រៀនភាសាតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានបញ្ចូលក្នុងមេរៀនគ្រប់ថ្នាក់នីមួយៗ

ក្នុងគោលបំណងដើម្បីឲ្យសិស្សទាំងអស់បានស្តាប់, ទស្សនាកំរងមេរៀន និងហាត់បញ្ចេញសំលេង

ឲ្យបានត្រឹមត្រូវ។

យើងខ្ញុំបានខិតខំទំនាក់ទំនងរកគ្រូបង្រៀនស្ម័គ្គចិត្តជាច្រើនមកពីតាមប្រទេសផ្សេងៗដើម្បីជួយបង្រៀននិង

ផ្តល់ឱកាសឱ្យសិស្សបានហ្វឹកហាត់អភិវឌ្ឍសមត្ថភាពផ្នែកស្តាប់និងបញ្ចេញសំលេងជាមួយគ្រូបរទេសដោយផ្ទាល់ផ្ទាល់ផងដែរ។

ក្រុមការងារយើងខ្ញុំនៅតែបន្តយកចិត្តទុកដាក់ទៅលើអនាម័យ មុនពេលចូលរៀន តាមការណែនាំរបស់ក្រសួងអប់រំ និង ក្រសួងសុខាភិបាល ។

លោកគ្រូអ្នកគ្រូបានបង្រៀនសិស្សតាមកាលវិភាគដែលសាលាបានកំណត់ទៅតាមម៉ោងសិស្សដែលបានកំណត់។

ជាពិសេស**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** យើងខ្ញុំបានចូលរួមរាល់សកម្មភាពជាមួយអាជ្ញាធរដូចជា៖ ការសំអាតស្អានផ្តល់អំណោយផ្សេងៗនិងបានចូលរួមប្រជុំប្រចាំខែជាមួយមូលដ្ឋានភូមិឃុំស្រុកនិងចូលរួមគ្រប់សកម្មភាពផ្សេងៗផងដែរ។

យើងមានការប្រជុំជាមួយបុគ្គលិកជារៀងរាល់ខែ ហើយក៏មានការចូលរួមប្រជុំជាមួយអង្គការសង្គមស៊ីវិល និង អង្គភាពផ្សេងៗទៀតជាប្រចាំ។

ម៉្យាងទៀតខាង**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** របស់យើងក៏មានការហ្វឹកហាត់ (teachers training course) ដើម្បីអភិវឌ្ឍន៍សមត្ថភាពគ្រូបង្គោលអំពីការបង្រៀនសិស្សអោយមានភាពរីកចំរើនផងដែរ។

## ក.៦ លទ្ធផលសំរេចបាន

គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ថ្វីត្បិតតែមានសិស្សខ្លះៗរៀនមិនសូវបានជិតដល់ប៉ុន្តែសិស្សជាង៩០%បានប្រលងជាប់និងបានបន្តទៅថ្នាក់កម្រិតខ្ពស់ជាងមុនគួរអោយសរសើរ   លើសពីនេះទៅទៀតយើងឃើញថាមាតាបិតាសិស្សក៏មានការចូលរួមច្រើនផងដែរ នៅពេលដែរអង្គការត្រូវការជំនួយពីពួកគាត់ម្តងៗ។

អាសយដ្ឋាន ៖ ផ្ទះលេខ............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ   ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008  Email: pagna.pcef.cambodia@gmail.com

## ខ. ការចូលរួមប្រជុំនិងវគ្គបណ្តុះបណ្តាល

### ខ.១ គោលបំណង

ដើម្បីស្តាប់យល់ដឹងអំពីច្បាប់និងបញ្ហារមួយចំនួនពីថ្នាក់ដឹកនាំនិងជាកិច្ចសហការដើម្បីជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ដើម្បីចូលរួមកាត់បន្ថយភាពអវិជ្ជា។

### ខ.២ បេសកកម្ម

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចូលរួមប្រជុំនិងវគ្គណ្តុះបណ្តាលដូចជា។

- ប្រជុំជាមួយក្រុមការងាររបស់ខ្លួនពីរដងរៀងរាល់ខែ និងបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនដើម្បីឈានទៅរកភាពរីកចំរើនសមត្ថភាពមួយដងក្នុងមួយខែជាប្រចាំ។
- ប្រជុំសិក្សានុសិស្សដើម្បីយល់ដឹងពីច្បាប់វិន័យរបស់សាលាព្រមទាំងបញ្ជៀតចូលនៅសុជីវធម៌សិលធម៌ និង ភូមិឃុំមានសុវត្ថិភាពផងដែរ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏មានការជួបប្រជុំជាមួយអាណាព្យាបាលសិស្សពីរដងក្នុងមួយឆ្នាំដើម្បីពិភាក្សាអំពីភាពរីកចំរើននិងបញ្ហារមួយចំនួនដែលបានកើតឡើងផងដែរ។
- ចូលរួមប្រជុំប្រចាំខែជាមយយក្រុមប្រឹក្សាឃុំជារៀងរាល់ខែ។
- អង្គការយើងខ្ញុំក៏បានចូលរួមប្រជុំជាមួយថ្នាក់ស្រុកជារឿយៗផងដែរ។
- ប្រជុំថ្នាក់ខេត្តជាមួយក្រុមប្រឹក្សាខេត្តពីរដងក្នុងមួយឆ្នាំ និងប្រជុំថ្នាក់ខេត្តជាមួយ វ.ស.ស ពីរដងក្នុងមួយឆ្នាំផងដែរ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចូលរួមវគ្គបណ្តុះបណ្តាលជាមួយ **ជ.គ.ប** ដើម្បីធ្វើជាអ្នកស្ម័គ្គចិត្តសង្កេតការណ៍បោះឆ្នោត ក្នុងអាណត្តបន្តបន្ទាប់ក្រោយៗទៀត។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏បានចូលរួមប្រជុំជាច្រើនទៀត ដូចជា ប្រជុំតាមសាលារដ្ឋមួយចំនួនក្នុងតំបន់គោលដៅ និងប្រជុំបណ្តាញអង្គការនិងសមាគម ។ល។

## គ. ជួសជុលនិងសាងសង់

### គ.១ គោលបំណង

ដើម្បីផ្តល់ភាពងាយស្រួលនិងសុវត្ថិភាពដល់សិក្សានុសិស្ស ជាពិសេសដើម្បីមានបន្ទប់អង្គុយរៀនបានស្រួលបួល យើងខ្ញុំបានរៃអង្គាសថវិការពីសប្បុរសជននានាដើម្បីសាងសង់សាលារៀនមួយខ្នងមានបីបន្ទប់បានដោយជោគជ័យនិងជួសជុលបន្ទប់ចាស់មួយដើម្បីទ្រៀមគម្រោងបង្រៀនកុំព្យូទ័រសម្រាប់ឆ្នាំបន្ត២០២៥។

## គ.២ បញ្ហាប្រឈម និងដំណោះស្រាយ

### គ.៣. បញ្ហាប្រឈម

- ខ្វះថវិការផ្ដល់គ្រូបន្ថែមដោយសារតែមានកំណើនសិស្សកើនឡើងៗជារៀងរាល់ឆ្នាំ ដែលជាហេតុធ្វើអោយយើងខ្វះគ្រូបង្គោលបន្ថែម។
- សមត្ថភាពគ្រូតាមមូលដ្ឋាននៅមានកម្រិត យើងខ្ញុំនៅតែត្រូវការអ្នកឧបត្ថម្ភសម្រាប់ការសិក្សារបស់គ្រូៗបន្ថែមទៀតនៅថ្នាក់សាកលវិទ្យាល័យ។

### គ.៤. ដំណោះស្រាយ

-យើងខ្ញុំនៅតែស្វែងរកសប្បុរសជនដើម្បីជួយឧបត្ថម្ភថ្លៃគ្រូបង្រៀននិងជួយថ្លៃសិក្សាគ្រូៗសម្រាប់រៀនបន្តនៅសាកវិទ្យាល័យ។

-អង្គការរបស់យើងខ្ញុំសូមធ្វើការអំពាវនាវដល់បងប្អូនសប្បុរសជន ក្នុងនិងក្រៅប្រទេសមេត្តាជួយឧបត្ថម្ភគាំទ្រដើម្បីអោយគម្រោងយើងខ្ញុំបានបន្តជួយបង្រៀនដល់កុមារក្រីក្រតាមជនបទបន្តទៀត។

-យើងខ្ញុំនៅតែបន្តរកវិធីសាស្ត្រដើម្បីជួយគ្រូៗមូលដ្ឋានអោយមានសមត្ថភាពប្រសើរឡើងតាមតែអាចធ្វើបាន។

## ឃ. សន្និដ្ឋាន

ទោះបីជាជួបប្រទះនៅបញ្ហាប្រឈមមួយចំនួន ក៏ដោយក៏គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** នៅតែមានដំណើរការជាបណ្ដើរៗ ពីមួយថ្ងៃទៅមួយថ្ងៃកំពុងមានសន្ទុះទៅមុខសំដៅទៅជួយដល់ការអភិវឌ្ឍធនធានមនុស្សជំនាន់ថ្មីរបស់យើងសម្រាប់បន្តវេននាពេលអនាគត ម្យ៉ាងវិញទៀតនៅក្នុងឆ្នាំ២០២៥ខាងមុខនេះយើងមានគ្រោងរកមូលនិធិដើម្បីបើកថ្នាក់កុំព្យូទ័រថ្នាក់មូលដ្ឋាន និងថ្នាក់ភាសារចិនផងដែរ ។

ថ្ងៃចន្ទ ៥រោង ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

សៀមរាប,ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥

**ប្រធានអង្គការ**

ស្រី សំឡូរ

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

--------

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

## របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤

| | | | |
|---|---|---|---|
| **មូលនិធិដើមគ្រា** | | | **$ 5,090.84** |
| **ទទួលបានពីម្ចាស់ជំនួយ ដូចជា៖** | | | |
| ១. មូលនិធិអាយហឺប (iHerb by CCAFO) | | | $ 17,971.70 |
| ២. បេវលី តាមរយៈ វ៉ាវ (Beverly by WOW) | | | $ 7,000.00 |
| ៣. ប្រាក់វិភាគទានផ្ទាល់ដៃ និង ហេះបរិច្ចាគ (Hand donation and donation box) | | | $ 1,399.45 |
| ៤. បរិច្ចាគពី ឌេប្រា ហ្គេន អូស្ត្រាលី (Donated from Debra Glen Australia ) | | | $ 3,108.50 |
| ៧. បរិច្ចាគពី តាមី អាយវ៉ាន( Donation from Tami Ivan ) | | | $ 475.00 |
| ១០. រៃអង្គាសតាមវេបសាយ ហ្គូហ្វាន់មី (Fundraing from GOFUNDME website) | | | $ 10,800.00 |
| ៧. ប្រាក់ការពីធនាគា (Bank Interest and income) | | | $ 0.70 |
| **មូលនិធិសរុប** | | | **$ 45,846.19** |

**ការចំណាយលើគំរោងនីមួយៗ**

| | | |
|---|---|---|
| ១. គម្រោងថ្នាក់ភាសាអង់គ្លេស | | $ 17,028.29 |
| ២. គម្រោងធានារ៉ាប់រងសុខភាព ប.ស.ស | | $ 1,012.07 |
| ៣. គម្រោងថ្នាក់បំប៉នជំនាញដល់គ្រូ | | $ 170.00 |
| ៤.អាហារសម្រន់ ប្រជុំបុគ្គលិក និង ជួបប្រជុំពិភាក្សាជាមួយមាតាបិតាសិស្ស | | $ 199.98 |
| ៥. ទឹកភ្លើង អ៊ីនធឺណិត កុំព្យូទ័រ និង វេបសាយ | | $ 3,379.26 |
| ៦. ជួសជុល និង សាងសង់ | | $ 22,738.55 |
| ៧. សម្ភារសាលា និងការិយាល័យ | | $ 748.71 |
| ៨. កាត់សេវាពីធនាគា(Banking Service's -AC Maintain Fee) | | $ 4.58 |
| ៩. ចំណាយផ្សេងៗ | | $ 519.29 |
| **សរុបចំណាយ** | | **$ 45,800.73** |
| | **ទឹកប្រាក់ចុងគ្រា** | **$ 45.46** |

បានឃើញ និង ឯកភាព

**ប្រធានអង្គការ**

ស្រី សំបូរ

ថ្ងៃចន្ទ ៥ រោច ខែមាឃ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨
សៀមរាប ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៥
**អ្នកធ្វើរបាយការណ៍**

**ជិម ចំរុង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

-------------

អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

## ព័ត៌មានអំពីគណនី

នៅក្នុងឆ្នាំ២០២៤ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** មានគណនីធនាគារចំនួនមួយ សម្រាប់ទទួលជំនួយ និងទូទាត់ រាល់ការចំណាយក្នុងប្រតិបត្តិការរបស់អង្គការដែលអនុវត្តដោយផ្ទាល់ ៖

**១- ធនាគារ អេស៊ីលីដា**

| **ឈ្មោះគណនី** | **លេខគណនី** | **មានទឹកប្រាក់នៅចុងគ្រាចំនួន** |
|---|---|---|
| **Cambodian Education Fund** | 34750214532411 | 3.24 ដុល្លារ<br>(ស្មើរនិង 13,041 រៀល) |

ថ្ងៃ ចន្ទ ៥រោច ខែមាឃ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

សៀមរាប, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៥

**ប្រធានអង្គការ**

ស្រី ឧបិស្សូរ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ២៥១២ សដណ

រាជធានីភ្នំពេញ,ថ្ងៃទី..១៤..ខែ...[illegible].....ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជម្រាបមក**
**លោក ស្រី សំបូ ប្រធានអង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា*** នៅក្រសួងមហាផ្ទៃ។

**យោង** : លិខិតលេខ *០០១* ចុះថ្ងៃទី***២៥*** ខែ***សីហា*** ឆ្នាំ***២០១៤*** ស្តីពីការសុំចុះបញ្ជីរបស់***អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា***។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា*** ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលនៅភូមិ***ល្វា*** ឃុំ***ក្របៅទង*** ស្រុក***ប្រាសាទបាគង*** ខេត្ត***សៀមរាប*** នោះហើយ។ ***អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ និងមិនស្វែងរកប្រាក់កម្រៃជាឯកជន។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីឱ្យបានត្រឹមត្រូវតាមច្បាប់។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន និងនាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុល លឹម**

***ចម្លងជូន:***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តសៀមរាប
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ